**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និង ដឹកជញ្ជូន**

លេខ: 220 សាធ.ដក សក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៦ ឆ្នាំ២០០២

# សេចក្ដីសំរេច

**ស្ដីពីការបង្កើតក្រុមការងារសហប្រតិបត្តការអភិវឌ្ឍន៍តំបន់ត្រីកោណ**
**កម្ពុជា-ឡាវ-វៀតណាម និង កម្ពុជា-ឡាវ-ថៃ**

---

## រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០.១១.១៩៩៤ ស្ដីពីសហលក្ខន្តិកៈមន្ត្រី-រាជការស៊ីវិល ។

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ខែមករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។

-បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

-បានឃើញ សេចក្ដីជូនដំណឹងលេខ ៦៣៥ សជណ.សរ ចុះថ្ងៃទី ២៥.០៤.២០០២ របស់ទីស្ដីការគណរដ្ឋមន្ត្រី ។

-យោងតាមការចាំបាច់របស់ក្រសួង ។

## <u>សំរេច</u>

**<u>ប្រការ ១:</u>** បង្កើតឡើងនូវក្រុមការងារសហប្រតិបត្តការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និង កម្ពុជា-ឡាវ-ថៃ ដូចមានសមាសភាពខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ឈិន គង់ហ៊ាន** | អគ្គនាយកសាធារណការ | ប្រធាន |
| ២-លោក **ចន្ទ្រ ពិសិដ្ឋ** | អគ្គនាយករងសាធារណការ | អនុប្រធាន |
| ៣-លោក **ទ៉ា ស៊ីម សុរិយា** | នាយក នាយកដ្ឋានផែនការ | សមាជិកសំរបសំរួលអចិន្ត្រៃយ៍ |
| ៤-លោក **លឹម ស៊ីដេនីន** | នាយក នាយកដ្ឋានផ្លូវថ្នល់ | សមាជិក |
| ៥-លោក **គីម បូរី** | នាយករង មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ | សមាជិក |
| ៦-លោក **ផែង សុចិន្ដាវោ** | នាយក នាយកដ្ឋានផ្លូវអាកាស | សមាជិក |
| ៧-លោក **យូ វ៉ា** | មន្ត្រីការិយាល័យអាស៊ាននាយកដ្ឋានផែនការ | សមាជិក |
| ៨-លោក **សួង ពិសិដ្ឋ** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តរតនៈគិរី | សមាជិក |
| ៩-លោក **ហ៊ុង ផាន់រឿន** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្ទឹងត្រែង | សមាជិក |
| ១០-លោក **ផាន់ សំអាន** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ | សមាជិក |

**ប្រការ ២:** ក្រុមការងារមានភារៈកិច្ចៈ

-ចូលរួមកិច្ចប្រជុំពិភាក្សាការងារ គណៈកម្មការសហប្រត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណលើវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

-ចូលរួមសិក្សាស្រាវជ្រាវរៀបចំផែនការ ទិសដៅយុទ្ធសាស្ត្រ និងអនុវត្តគំរោងការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក្នុងក្របខ័ណ្ឌ តំបន់ត្រីកោណ

-សំរបសំរួលការងារជាមួយក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធ ក្នុងក្រុមការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក្នុងតំបន់ត្រីកោណ

-បំពេញភារៈកិច្ចផ្សេងទៀតដែលគណៈកម្មការ និងក្រសួងប្រគល់អោយ

-ធ្វើរបាយការបូកសរុបលទ្ធផលការងារខាងលើ ជូនគណៈកម្មការ ជូនក្រសួង និងស្ថាប័ន ពាក់ព័ន្ធ

**ប្រការ ៣:** អគ្គនាយកសាធារណការ. នាយក មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ, នាយកនៃ នាយកដ្ឋានផែនការ នាយក នៃនាយកដ្ឋានផ្លូវថ្នល់ នាយកខុទ្ទកាល័យ នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត រតនគិរី, ស្ទឹងត្រែង, ព្រះវិហារ ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃប្រកាស អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ឃឹម ឆាយ៉ឹម

**ចំឡងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ដូចមាត្រា៣
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការបរទេស
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ឯកឧត្តមរដ្ឋលេខាធិការ
-ឯកឧត្តមអនុរដ្ឋលេខាធិការ
-ឯកឧត្តមអគ្គនាយក
-នាយកដ្ឋានបុគ្គលិកធនធានមនុស្ស
-សាមីខ្លួន "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ